សាលាឧទ្ធរណ៍
សំណុំរឿងព្រហ្មទណ្ឌ
លេខ ១១១
ចុះថ្ងៃទី ២៣-០១-២០១៧
សាលដីកា
លេខ ៥១ ក្រII "ល"
ចុះថ្ងៃទី ១២-០៦-២០១៧

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាឧទ្ធរណ៍ភ្នំពេញ

បង្កើតឡើងតាមច្បាប់ស្តីពីការរៀបចំអង្គការតុលាការដែលប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៥ ចុះថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ២០១៤ ។

បានបើកសវនាការជាអសាធារណៈ ៣ភាលសវនាការនៃសាលាឧទ្ធរណ៍ នៅថ្ងៃទី ២៤ ខែឧសភា ឆ្នាំ២០១៧ ដោយមានសមាសភាពដូចខាងក្រោម៖

### សមាសភាពក្រុមប្រឹក្សាជំនុំជម្រះ

លោកស្រី [redacted] ជាប្រធានក្រុមប្រឹក្សា
លោក [redacted] ជាចៅក្រមប្រឹក្សា
ឯកឧត្តម [redacted] ជាចៅក្រមប្រឹក្សា

### តំណាងមហាអយ្យការ

លោក [redacted] ជាព្រះរាជអាជ្ញា

### ក្រឡាបញ្ជីសវនាការ

កញ្ញា [redacted]

ដើម្បីជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍សំណុំរឿងព្រហ្មទណ្ឌលេខ ១១១ ចុះថ្ងៃទី២៣-០១-២០១៧ ដែលមាន៖

-ជនជាប់ចោទឈ្មោះ [redacted]ាយលី ភេទប្រុស អាយុ ៣៦ឆ្នាំ ជាតិខ្មែរ មុខរបរមេការសំណង់ កើតនៅទីក្រុងភ្នំពេញ មានទីលំនៅការដ្ឋានសំណង់សង្កាត់ជ្រោយចង្វារ ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] ហុង (ស) ម្តាយឈ្មោះ [redacted] (ស) ជានីតិជន ទោសពីមុនគ្មាន។ (ដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ២០៩៤ តព្រ ចុះថ្ងៃទី០៧-០៨-២០១៥) ។

មានលោក [redacted]វិសាល ជាមេធាវីការពារសិទ្ធិ

<u>ជាប់ចោទពីបទ</u> ការទិញពេស្យាកុមារ ប្រព្រឹត្តនៅចំណុចនៅក្នុងសណ្ឋាគារមួយ ជិតស្ពានជ្រោយចង្វារ ផ្លូវជាតិលេខ៥ កាលពីកន្លះឆ្នាំមុន។ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ៣៤ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted]ាលី ភេទប្រុស អាយុ ៣១ឆ្នាំ សញ្ជាតិអាមេរិក ទីលំនៅបច្ចុប្បន្ន ផ្ទះលេខ៧៨ ផ្លូវ១០BIS សង្កាត់ផ្សារដើមថ្កូវ ខណ្ឌចំការមន រាជធានីភ្នំពេញ។

-ជនរងគ្រោះឈ្មោះ [redacted]ណារី ភេទស្រី កើតថ្ងៃទី១០ ខែមេសា ឆ្នាំ២០០២ ជាតិខ្មែរវៀតណាម ទីលំនៅសព្វនៅ





Scanned by CamScanner

[redacted]។

មានលោកស្រី[redacted]សូនី ជាមេធាវីតំណាងដោយអាណត្តិ។

បណ្តឹងឧទ្ធរណ៍លេខ ៨២១ ចុះថ្ងៃទី ១១ ខែវិច្ឆិកា ឆ្នាំ២០១៦ របស់ឈ្មោះ [redacted]ឆាយលី ជាជនជាប់ចោទ ប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ៤៥២ "វ" ក្រ៧ ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១៥ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុចសេចក្តីសម្រេចទាំងមូល។

## ៦រឿងហេតុមានដូចតទៅ

ឈ្មោះ[redacted]ណារី ដែលជាជនរងគ្រោះបានរស់នៅជាមួយយាយតា និងមីងៗឈ្មោះ[redacted]ស្រស់ និងឈ្មោះ[redacted] ទីណា។ ឈ្មោះ[redacted] ណារី មិនបានរស់នៅជាមួយឪពុកម្តាយទេដោយសារម្តាយរបស់នាងរត់ចោលបាត់ ចំណែកឪពុកមានជំងឺសរសៃប្រសាទ ទើបរស់នៅជាមួយយាយតា និងមីងៗ ហើយបានរៀនដល់ថ្នាក់ទី៥។ កាលពីរយៈពេលប្រហែលកន្លះឆ្នាំមុន ឈ្មោះ [redacted]ស្រស់ ត្រូវជាមីរបស់ឈ្មោះ[redacted] ណារី បាននាំឈ្មោះ [redacted]ណារី ទៅធ្វើកម្មករសំណង់ជាមួយ រួចឈ្មោះ[redacted] ស្រស់ បាននិយាយត្រូវរ៉ូវគ្នាជាមួយមេការសំណង់ឈ្មោះ[redacted]ឆាយលី ថាលក់ព្រហ្មចារី និងនាំឈ្មោះ [redacted] ណារី ទៅជួបឈ្មោះ[redacted]ឆាយលី នៅសណ្ឋាគារជិតស្ពានជ្រោយចង្វារផ្លូវជាតិលេខ៥។ ឈ្មោះ [redacted] ឆាយលី បានរួមភេទជាមួយឈ្មោះ [redacted]ណារី ទាំងបង្ខំចំនួន មួយដង ហើយនៅពេលយប់ឈ្មោះ[redacted]ឆាយលី បានឱ្យលុយទៅឈ្មោះ[redacted]ស្រស់ ចំនួន ១០០០$។ លុះថ្ងៃទី១៣ ខែសីហា ឆ្នាំ២០១៥ ឈ្មោះ[redacted] ទីណា ត្រូវជាមីងរបស់ឈ្មោះ [redacted] ណារី បានយកសោករ និងច្រវ៉ាក់មកចាក់ជាប់ជើងរបស់ឈ្មោះ[redacted]ណារី ឱ្យនៅតែក្នុងផ្ទះ រហូតដល់ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៥ ទើបឈ្មោះ [redacted] ណារី បានរើសកូនសោរនៅក្នុងផ្ទះចាក់ត្រូវ រួចក៏ចេញពីផ្ទះ និងបានទៅផ្ទះមិត្តភក្តិចំនួន បីថ្ងៃ ទើបទៅសុំផ្ទះមីងលក់គុយទាវស្នាក់នៅនិងធ្វើជាកូនរបស់គាត់។

*បានឃើញ សាលក្រមព្រហ្មទណ្ឌលេខ ៤៥២ "វ" ក្រ៧ ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១៦ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលមានខ្លឹមសារដូចខាងក្រោម៖*

១. ផ្តន្ទាទោស៖

ក-ឈ្មោះ[redacted]ស្រស់ ភេទស្រី អាយុ ៣២ឆ្នាំ ជាតិខ្មែរឥស្លាម ដាក់ពន្ធនាគារកំណត់ ០៣ (បី)ឆ្នាំ ពីបទ: អំពើអាសអាភាសលើកុមារ ប្រព្រឹត្តនៅសណ្ឋាគារមួយជិតស្ពានជ្រោយចង្វារ ផ្លូវជាតិលេខ៥ កាលពីអំឡុងឆ្នាំ២០១៤។ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ៣៥ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ។

ខ-ឈ្មោះ [redacted] ទីណា ភេទស្រី អាយុ ២៧ឆ្នាំ ជាតិខ្មែរឥស្លាម ដាក់ពន្ធនាគារកំណត់ ០៣ (បី)ឆ្នាំ ពីបទ ការបង្ខាំង ប្រព្រឹត្តនៅចំណុចផ្ទះលេខ៧ ផ្លូវជាតិលេខ៥ ភូមិទី៥ សង្កាត់ច្រាំងចម្រេះ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ កាលពីថ្ងៃទី០៣ ខែសីហា ឆ្នាំ២០១៥។ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោស តាមមាត្រា ២១ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ។



Scanned by CamScanner

គ-ឈ្មោះ [redacted] ឆាយលី ភេទប្រុស អាយុ ៣៦ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ ០៣ (បី)ឆ្នាំ និង០៦ (ប្រាំមួយ)ខែ ពីបទ ការទិញពេស្យាកុមារ ប្រព្រឹត្តទៅចំណុចក្នុងសណ្ឋាគារមួយជិតស្ពានជ្រោយចង្វារ ផ្លូវជាតិលេខ៥ កាលពីអំឡុងឆ្នាំ២០១៤។ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ៣៤ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ។

២- វត្ថុចាប់យកត្រូវរឹបអូសតាមមាត្រា៦២ និងមាត្រា៦៣ នៃក្រមព្រហ្មទណ្ឌគឺច្រវ៉ាក់មួយខ្សែរប្រវែង ០២ម៉ែត្រ និងមេសោរចំនួន ០២។

៣-វត្ថុចាប់យកត្រូវប្រគល់ឱ្យម្ចាស់ដើមវិញគឺ ១-ទូរស័ព្ទម៉ាកណូគាពណ៌ខៀវ-ខ្មៅ មានស៊ីមលេខ ០៩៧ ៧៩ ៧៤ ២១៦ ៦ ចំនួន ០១គ្រឿង ២-ម៉ូតូម៉ាកសេ១០០កូរ៉េ ពណ៌ក្រហមពាក់ស្លាកលេខ ថ-៣៦៧១ ភ.៣១ (យោងលើកាតគ្រីជាក់ស្តែងគ្មានស្លាកលេខ)ចំនួន ០១គ្រឿង និង៣-លុយចំនួន ១០០$ (មួយរយដុល្លារអាមេរិក)

៤-ឱ្យជនជាប់ចោទឈ្មោះ [redacted] ឆាយលី សងសំណងជម្ងឺចិត្តទៅដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] អ៊ែនម៉ីហេង ចំនួន ៨.០០០.០០០ ៛(ប្រាំបីលានរៀលគត់) ការទាមទារលើសពីនេះត្រូវលើកចោល។

សាលក្រមនេះជំនុំជម្រះជាសាធារណៈថ្ងៃទី១១ ខែមីនា ឆ្នាំ២០១៦ និងប្រកាសជាសាធារណៈ ថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១៦ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] ស្រស់ ឈ្មោះ [redacted] ទីណា និងឈ្មោះ [redacted] ឆាយលី ចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] អ៊ែនម៉ីហេង។

ទុកសិទ្ធិប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

បានឃើញ របាយការណ៍រឿងព្រហ្មទណ្ឌ ចុះថ្ងៃទី ២៣-០២-២០១៧ របស់សាលាឧទ្ធរណ៍ ។

បានឃើញ សេចក្តីសន្និដ្ឋាន ចុះថ្ងៃទី ២២-០៥-២០១៧ របស់មហាអយ្យការអមសាលាឧទ្ធរណ៍។

បានឃើញ ដីកាចាត់តាំងសមាសភាពក្រុមប្រឹក្សាជំនុំជម្រះទី២លេខ ២៦ ដក២០១៧ ចុះថ្ងៃទី០៩-០៥-២០១៧។

## នាពេលសវនាការ

-ប្រធានក្រុមប្រឹក្សាអានរបាយការណ៍សង្ខេបរឿង

-ជនជាប់ចោទឈ្មោះ [redacted] ឆាយលី បានឆ្លើយថា ខ្លួនប្តឹងឧទ្ធរណ៍ដោយសារតែខ្លួនមិនបានប្រព្រឹត្តដូចការចោទប្រកាន់ទេ។ មុនភ្ជាប់ពាក្យខ្លួនមិនបានឱ្យលុយកាក់គាត់ទេ តែគាត់ខឹងខ្លួនដោយសារខ្លួនស្តីឱ្យគាត់ខ្លាំងៗ។ លុយដែលខ្លួនឱ្យគាត់គឺសម្រាប់ភ្ជាប់ពាក្យ។ លុយមួយពាន់ដុល្លារនោះគឺខ្លួនឱ្យទៅឈ្មោះ [redacted] ណារី មុនពេលភ្ជាប់ពាក្យមួយថ្ងៃ ឬពីរថ្ងៃ គឺដើម្បីទិញឥវ៉ាន់ភ្ជាប់ពាក្យ។ ខ្លួនស្គាល់ដណ្តឹង នាងពីមីង និងតារបស់នាង ពេលភ្ជាប់ពាក្យគឺមានបំពាក់ចិញ្ចៀន ខ្សែកក្រវិលគឺខ្លួនទិញឱ្យ ពេលភ្ជាប់ពាក្យមានអ្នកជិតខាងដឹងឮ តែមិនបានថតរូបទេ។ ការភ្ជាប់ពាក្យដោយការស្រលាញ់ខ្លួនស្គាល់នាងមុនភ្ជាប់ពាក្យបានប្រាំមួយខែ ខ្លួនមិនដឹងពីវាយុរបស់នាងទេ គ្រាន់តែឃើញនាងពេញរូបពេញរាង ហើយនាងធ្វើការរោងចក្រពីរបីហើយ។ ខ្លួនមិនបានបង្ខំរួមភេទ ហើយក៏មិនធ្លាប់រួមភេទជាមួយឈ្មោះ ណារី ទេ។ យើងធ្លាប់ដើរលេងជាមួយគ្នាលក្ខណៈគ្រួសារ និងធ្លាប់ទៅញ៉ាំកាហ្វេជាមួយគ្នា។ ក្រោយភ្ជាប់ពាក្យយូរណាស់ទើបគេប្តឹងខ្លួន។ សំណូមពរឱ្យតុលាការជួយរកយុត្តិធម៌ឱ្យខ្លួនផង។



Scanned by CamScanner

-ជនរងគ្រោះឈ្មោះ [redacted] ណារី បានឆ្លើយថា ខ្លួនមានអាយុ ១៥ឆ្នាំ ពេលនេះស្នាក់នៅអង្គការយុត្តិធម៌ និងក្ដីសង្ឃឹម។ ពីមុនមកខ្លួនរស់នៅជាមួយមីង និងយាយ តា ពេលនៅជាមួយគាត់ខ្លួនរៀនបានថ្នាក់ទី៥ ហើយក៏ឈប់រៀន និងទៅធ្វើការសំណង់ជាមួយគាត់។ មីងឈ្មោះ [redacted] ស្រស់ បានឱ្យខ្លួនស្លៀកពាក់ហើយទៅជាមួយគាត់ ដោយគាត់នាំខ្លួនទៅសណ្ឋាគារ ពេលទៅដល់គាត់បានហៅ តាលី ហើយឱ្យខ្លួនស្នាក់នៅបន្ទប់មួយជាមួយ តាលី ហើយគាត់អោបខ្លួន ពេលនោះខ្លួនរត់ចេញមកតែមីងរបស់ខ្លួនបង្ខំខ្លួនចូលទៅវិញ ហើយមីងខ្លួនរត់ទៅពួននៅបន្ទប់ទឹក ហើយតាលី រំលោភខ្លួនបានម្តង។ ក្រោយកើតហេតុបាន ពីរ-បីថ្ងៃ គាត់មកដណ្តឹងខ្លួន តែខ្លួនមិនព្រមទេ ប៉ុន្តែមីងបង្ខំ ។ រឿងនេះខ្លួនមិនដែលបានប្រាប់អ្នកណាទេ។ ក្រោយមកខ្លួនទៅធ្វើការរោងចក្រ ហើយក៏បានទៅខួបកំណើតមិត្តភក្តិមិនបានចូលផ្ទះទេ ពេលចូលមកវិញមីងគាត់យកសោរមកចាក់ជើងរបស់ខ្លួន បន្ទាប់មកខ្លួនបានលួចយកសោរចាក់ជើងរួចរត់ទៅផ្ទះមិត្តភក្តិនៅគីឡូ៦ ។ ក្រោយពេលតាលី រំលោភខ្លួនរួចតាលីបានឱ្យលុយមីងរបស់ខ្លួនចំនួន ១០០០$ នៅសណ្ឋាគារនោះ ខ្លួនដឹងថាលុយនោះ១០សន្លឹកព្រោះគាត់ រាប់លុយឱ្យម៉ីខ្លួន ហើយម៉ីខ្លួនមិនដែលនិយាយពីបញ្ហាលុយនេះទេ។ ខ្លួនពិតជាធ្លាប់ដើរលេងជាមួយគាត់មែន តែក្រោយពេលកើតហេតុទេ។ ខ្លួនស្គាល់តាលី តាំងពីខ្លួននៅតូចដោយសារតែមីងខ្លួនធ្វើការជាមួយគាត់។ លុយដែលថាឱ្យភ្ជាប់ពាក្យនោះខ្លួនមិនដឹងទេ ។ ខ្លួនមិនដែលដើរលេងដាច់យប់ទេ។ ក្រោយកើតហេតុខ្លួនមិនបានប្តឹងដោយសារតែខ្លួនមិនហ៊ានប្តឹង។ សូមឱ្យតុលាការសម្រេចតាមច្បាប់។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted]វីត បាលី បានឆ្លើយដោយមានអ្នកបកប្រែអមថា សំណូមពរឱ្យតុលាការសុំស្វែងរកយុត្តិធម៌ឱ្យជនរងគ្រោះ និងព្រមទទួលយកសំណងដែលសាលាដំបូងបានសម្រេចឱ្យ។

-សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងមហាអយ្យការដែលសន្និដ្ឋានថា បណ្តឹងឧទ្ធរណ៍របស់ជនជាប់ចោទឃើញថាធ្វើឡើងត្រឹមត្រូវតាមទម្រង់ច្បាប់យោងមាត្រា៣៧៥ និងមាត្រា ៣៨២ថ្មី នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ រឿងនេះគឺមានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់ ដែលស៊ីសង្វាក់គ្នាចម្លើយរបស់ជនរងគ្រោះ និងអង្គហេតុ សំណូមពរឱ្យក្រុមប្រឹក្សាសម្រេចតម្កល់សាលក្រមរបស់សាលាដំបូងទុកជាបានការដដែល។

-លោកស្រី [redacted]ឃូនី ជាមេធាវីតំណាងឱ្យដើមបណ្តឹងរដ្ឋប្បវេណីសន្និដ្ឋានថា ពិតជាមានអង្គហេតុទិញពេស្យាកុមារមែន បើទោះបីជាជនជាប់ចោទប្រកែកដោះសារ ប៉ុន្តែផ្អែកលើភស្តុតាងក្នុងសំណុំរឿង ចម្លើយរបស់ជនជាប់ចោទនៅប៉ូលីស និងជនជាប់ចោទផ្សេងទៀត។ ម្យ៉ាងវិញទៀត ចម្លើយជនជាប់ចោទថា ឈ្មោះ [redacted] ណារី ធ្លាប់ដើរលេង និងរួមភេទជាមួយខ្លួនបានម្តងនោះ ចម្លើយទាំងនេះស៊ីសង្វាក់ និងភស្តុតាងនានាក្នុងសំណុំរឿង និងកោសលវិច័យ បង្ហាញឱ្យឃើញថាមានអង្គហេតុ ហើយក៏មានប៉ូលីសបានចូលបំភ្លឺ។ អំពើរបស់ជនជាប់ចោទគឺជាអំពើទិញពេស្យាកុមារតាមមាត្រា៣៤ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើរាជីវកម្មផ្លូវភេទ។ នៅពេលកើតហេតុជនរងគ្រោះមានអាយុ១២ឆ្នាំ គប្បីផ្តន្ទាទោសតាមមាត្រា ៣៤ កថាខណ្ឌទី២ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើរាជីវកម្មផ្លូវភេទ។ ស្នើសុំឱ្យតម្កល់សាលក្រមរបស់សាលាដំបូងទុកជាបានការដដែល។



Scanned by CamScanner

-លោក [redacted]សាល ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទសន្និដ្ឋានថា ខ្លួនសូមឱ្យក្រុមប្រឹក្សាសម្រេចឱ្យកូនក្តីខ្លួនរួចផុតពីបទចោទប្រកាន់ដោយហេតុថាភស្តុតាងដាក់បន្ទុកលើកូនក្តីខ្លួនគឺមិនគ្រប់គ្រាន់ ពោះលទ្ធផលកោសលវិច័យគឺមិនបានបញ្ជាក់ថាកូនក្តីខ្លួនជាអ្នកប្រព្រឹត្តទេ ហើយសាក្សីក៏បានឆ្លើយបញ្ជាក់ថាជនរងគ្រោះពិតជាពូកែដើរលេង។ ជនរងគ្រោះមានរូបរាងធំ ហើយធ្លាប់ធ្វើជាកម្មកររោងចក្រ ដូច្នេះកូនក្តីខ្លួនមិនអាចដឹងពីអាយុរបស់ជនរងគ្រោះទេ។ ជនរងគ្រោះធ្លាប់ដើរលេងជាមួយកូនក្តីខ្លួន ហើយបើកូនក្តីខ្លួនបានរួមភេទជាមួយជនរងគ្រោះមែនគាត់នឹងមិនភ្ជាប់ពាក្យជាមួយជនរងគ្រោះទេ ហើយការដែលគាត់អះអាងថាកូនក្តីខ្លួនឱ្យលុយមួយពាន់ដុល្លារនោះមិនដឹងគាត់ឱ្យក្នុងគោលបំណងអ្វីទេ ហេតុអ្វីមកចោទប្រកាន់កូនក្តីខ្លួនថាឱ្យលុយជាថ្នូរនឹងការរួមភេទ។ វិមតិសង្ស័យបានជាប្រយោជន៍ដល់ជនជាប់ចោទយោងតាមមាត្រា៣៨ នៃរដ្ឋធម្មនុញ្ញ និង មាត្រា ៣៥១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

*ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ*

*ក្រោយពីបានស្តាប់ចម្លើយរបស់ជនរងគ្រោះ*

*ក្រោយពីបានស្តាប់ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី*

*ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ*

*ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីតំណាងឱ្យដើមបណ្តឹងរដ្ឋប្បវេណី*

*ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ*

*ក្រោយពីបានពិចារណាលើគ្រប់ឯកសារ និងភស្តុតាងផ្សេងៗ*

*ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ*

## <u>សាលាឧទ្ធរណ៍</u>

## <u>យល់ឃើញថា</u>

១-បណ្តឹងឧទ្ធរណ៍លេខ ៨២១ ចុះថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០១៦ របស់ឈ្មោ[redacted] ឆាយលី ជាជនជាប់ចោទប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ៤៥២ “វ” ក្រ៧ ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១៥ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុចសេចក្តីសម្រេចទាំងមូល បណ្តឹងនេះធ្វើឡើងក្នុងកំណត់ច្បាប់ សាលាឧទ្ធរណ៍អាចលើករឿងនេះយកមកជំនុំជម្រះបាន យោងតាមមាត្រា ៣៧៦ និងមាត្រា ៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

២-ជនជាប់ចោទឈ្មោះ [redacted]ឆាយលី បានឆ្លើយថា ខ្លួនមិនបានរួមភេទជាមួយជនរងគ្រោះ ហើយក៏មិនធ្លាប់បង្ខំរួមភេទជាមួយជនរងគ្រោះដែរ។ លុយ ១០០០ ដុល្លារ ដែលខ្លួនឱ្យទៅជនរងគ្រោះនោះ គឺជាលុយសម្រាប់ភ្ជាប់ពាក្យទេ ជនរងគ្រោះជាគូដណ្តឹងរបស់ខ្លួន ខ្លួនស្តីដណ្តឹងនាងពីតា និងមីងៗរបស់នាង ដោយបានធ្វើពិធីតាមប្រពៃណីនិងមានអ្នក



Scanned by CamScanner

ជិតខាងដឹងឮ។ ខ្ញុំមិនដឹងថានាងមានអាយុប៉ុន្មាននោះទេ គ្រាន់តែដឹងថានាងធ្វើការងាររោងចក្រពីរបីហើយ។

ក្រុមប្រឹក្សាយល់ឃើញថា ការឆ្លើយបដិសេធនេះមិនមានមូលដ្ឋានឱ្យក្រុមប្រឹក្សាពិចារណានោះទេ ដោយហេតុថា ជនជាប់ចោទដដែលបានឆ្លើយបញ្ជាក់នៅចំពោះមុខសមត្ថកិច្ចថាពិតជាបានរួមភេទជាមួយជនរងគ្រោះ ដែលមានអាយុ ១៤ ឆ្នាំ ហើយបានឱ្យលុយទៅឈ្មោ[redacted]ស្រស់ ចំនួន ១០០០ដុល្លារមែន ដែលចម្លើយនេះស៊ីសង្វាក់គ្នាជាមួយចម្លើយរបស់ឈ្មោះ [redacted]ស្រស់ ចម្លើយរបស់ជនរងគ្រោះ និងភស្តុតាងនានាក្នុងសំណុំរឿងបញ្ជាក់ថា ជនជាប់ចោទពិតជាបានធ្វើសកម្មភាពរួមភេទជាមួយជនរងគ្រោះ ហើយបានឱ្យលុយ ១០០០ ដុល្លារ ទៅឈ្មោ[redacted]ស្រស់ ដើម្បីជាថ្នូរនឹងការរួមភេទនេះ ។

៣-តាមចម្លើយជនរងគ្រោះឈ្មោះ [redacted] ណារី បានឆ្លើយថា ជនជាប់ចោទបានចាប់បង្ខំរួមភេទជាមួយខ្លួនដោយបានឱ្យលុយទៅមីងរបស់ខ្លួនចំនួន ១០០០ ដុល្លារ ជាថ្នូរនឹងការរួមភេទនេះ ។ ក្រុមប្រឹក្សាយល់ឃើញថា ចម្លើយរបស់ជនរងគ្រោះអាចឱ្យក្រុមប្រឹក្សាយកធ្វើជាមូលដ្ឋានក្នុងការពិចារណាបាន ដោយចម្លើយនេះស៊ីសង្វាក់ទៅនឹងចម្លើយរបស់ជនជាប់ចោទនៅចំពោះមុខសមត្ថកិច្ច និងសាក្សី និងភស្តុតាងនានា និងស៊ីសង្វាក់ទៅនឹងអង្គហេតុ ។

៤-តាមចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីឆ្លើយថា សំណូមពរសុំស្វែងរកយុត្តិធម៌ឱ្យជនរងគ្រោះ និងព្រមទទួលយកសំណងដែលសាលាដំបូងបានសម្រេចឱ្យ ។ គប្បីក្រុមប្រឹក្សាពិចារណា និងសម្រេចតាមការស្នើសុំ ។

៥-ក្រុមប្រឹក្សាយល់ឃើញថា ជនជាប់ចោទឈ្មោ[redacted]ឆាយលី ពិតបានចាប់បង្ខំរួមភេទជាមួយជនរងគ្រោះឈ្មោះ [redacted] ណារី ហើយជនរងគ្រោះជាអនីតិជនមានអាយុក្រោម១៥ឆ្នាំផ្អែកតាមសំបុត្របញ្ជាក់កំណើត (ឯកសារ ២/៤) ហើយបានឱ្យលុយទៅឈ្មោះ [redacted] ស្រស់ ចំនួន ១០០០ ដុល្លារ ជាថ្នូរនឹងការរួមភេទនេះ ។ អំពើរបស់ជនជាប់ចោទជាបទ ទិញពេស្យាកុមារ ដែលត្រូវបានបញ្ញត្តិឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៤ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើអាជីវកម្មផ្លូវភេទ។

៦-សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងមហាអយ្យការដែលសន្និដ្ឋានថា បណ្តឹងឧទ្ធរណ៍របស់ជនជាប់ចោទឃើញថាធ្វើឡើងត្រឹមត្រូវតាមទម្រង់ច្បាប់យោងមាត្រា៣៧៥ និងមាត្រា ៣៨២ថ្មី នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ រឿងនេះគឺមានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់ ដែលស៊ីសង្វាក់គ្នាចម្លើយរបស់ជនរងគ្រោះ និងអង្គហេតុ សំណូមពរឱ្យក្រុមប្រឹក្សាសម្រេចតម្កល់សាលក្រមរបស់សាលាដំបូងទុកជាបានការដដែល ។ គប្បីក្រុមប្រឹក្សាពិចារណា ។

៧-សេចក្តីសន្និដ្ឋានប្តឹងសុំរបស់មេធាវីតំណាងឱ្យដើមបណ្តឹងរដ្ឋប្បវេណីដែលសន្និដ្ឋានថា ពិតជាមានអង្គហេតុទិញពេស្យាកុមារមែន បើទោះបីជាជនជាប់ចោទប្រកែកដោះសារ ប៉ុន្តែផ្អែកលើភស្តុតាងក្នុងសំណុំរឿង ចម្លើយរបស់ជនជាប់ចោទនៅប៉ូលីស និងជនជាប់ចោទផ្សេងទៀត។ ម្យ៉ាងវិញទៀតចម្លើយជនជាប់ចោទថាឈ្មោះ [redacted] ណារី ធ្លាប់ដើរលេង និងរួមភេទជាមួយខ្លួនបានម្តងនោះ ចម្លើយទាំងនេះស៊ីសង្វាក់ភស្តុតាង និងកោសលវិច័យ បង្ហាញឱ្យឃើញ



Scanned by CamScanner

ថាមានអង្គហេតុ ហើយក៏មានប៉ូលិសបានចូលបំភ្លឺ ។ អំពើរបស់ជនជាប់ចោទគឺជាអំពើទិញពេស្យាកុមារតាមមាត្រា ៣៤ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើអាជីវកម្មផ្លូវភេទ។ នៅពេលកើតហេតុជនរងគ្រោះមានអាយុ ១២ ឆ្នាំ គប្បីផ្តន្ទាទោសតាមមាត្រា ៣៤ កថាខណ្ឌទី២ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើអាជីវកម្មផ្លូវភេទ។ ស្នើសុំឱ្យតម្កល់សាលក្រមរបស់សាលាដំបូងទុកជាបានការដដែល។ ក្រុមប្រឹក្សាយល់ឃើញថា សេចក្តីសន្និដ្ឋាននេះត្រឹមត្រូវតាមអង្គហេតុ និងអង្គច្បាប់ គប្បីក្រុមប្រឹក្សាលើកយកមកពិចារណាបាន។

៨-សេចក្តីសន្និដ្ឋានប្តឹងសុំរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទដែលសន្និដ្ឋានថា ខ្លួនសូមឱ្យក្រុមប្រឹក្សាម្រេចឱ្យកូនក្តីខ្លួនរួចផុតពីបទចោទប្រកាន់ដោយហេតុថាភស្តុតាងដាក់បន្ទុកលើកូនក្តីខ្លួនគឺមិនគ្រប់គ្រាន់ ព្រោះលទ្ធផលកោសលវិច័យគឺមិនបានបញ្ជាក់ថាកូនក្តីខ្លួនជាអ្នកប្រព្រឹត្តទេ ហើយសាក្សីក៏បានឆ្លើយបញ្ជាក់ថាជនរងគ្រោះពិតជាពូកែដើរលេង។ ជនរងគ្រោះមានរូបរាងធំ ហើយធ្លាប់ធ្វើជាកម្មកររោងចក្រ ដូច្នេះកូនក្តីខ្លួនមិនអាចដឹងពីអាយុរបស់ជនរងគ្រោះទេ។ ជនរងគ្រោះធ្លាប់ដើរលេងជាមួយកូនក្តីខ្លួន ហើយបើកូនក្តីខ្លួនបានរួមភេទជាមួយជនរងគ្រោះមែនគាត់នឹងមិនភ្ជាប់ពាក្យជាមួយជនរងគ្រោះទេ ហើយការដែលគាត់អះអាងថាកូនក្តីខ្លួនឱ្យលុយមួយពាន់ដុល្លារនោះមិនដឹងគាត់ឱ្យក្នុងគោលបំណងអ្វីទេ ហេតុអ្វីមកចោទប្រកាន់កូនក្តីខ្លួនថាឱ្យលុយជាថ្នូរនឹងការរួមភេទ។ វិមតិសង្ស័យបានជាប្រយោជន៍ដល់ជនជាប់ចោទយោងតាមមាត្រា៣៨ នៃរដ្ឋធម្មនុញ្ញ និង មាត្រា ៣៥១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

ក្រុមប្រឹក្សាយល់ឃើញថា ការសន្និដ្ឋាននេះមិនត្រឹមត្រូវតាមអង្គហេតុ និងអង្គច្បាប់ទេ ដោយហេតុថា ក្នុងសំណុំរឿងនេះមានភស្តុតាងគ្រប់គ្រាន់អាចបង្ហាញឱ្យឃើញពីពិរុទ្ធភាពលើជនជាប់ចោទ ដោយផ្អែកទៅលើចម្លើយសារភាពរបស់ជនជាប់ចោទនៅចំពោះមុខសមត្ថកិច្ច យោងមាត្រា ១១៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចម្លើយនេះត្រូវតុលាការជឿរហូតដល់មានភស្តុតាងផ្ទុយ ប៉ុន្តែជនជាប់ចោទមិនមានភស្តុតាងផ្ទុយមកបង្ហាញតុលាការទេ។ ជាងនេះទៅទៀតតាមចម្លើយបញ្ជាក់របស់ជនជាប់ចោទផ្សេងទៀត និងភស្តុតាងបង្ហាញឱ្យឃើញថាជនជាប់ចោទពិតជាបានប្រព្រឹត្តដូចការចោទប្រកាន់មែន។ ចំពោះការលើកឡើងអំពីការដែលជាគូដណ្តឹង ធ្លាប់ដើរលេងជាមួយគ្នា ហើយការឱ្យប្រាក់មួយពាន់ដុល្លារមិនបញ្ជាក់ពីគោលបំណងរបស់កូនក្តីខ្លួនក្នុងការទិញពេស្យា គឺមិនអាចឱ្យក្រុមប្រឹក្សាលើកយកមកពិចារណាបានទេ ដោយហេតុថាតាមចម្លើយរបស់ជនរងគ្រោះបានបញ្ជាក់ថាក្រោយពេលដែលជនជាប់ចោទបានចាប់រំលោភខ្លួនបានប្រគល់ប្រាក់មួយពាន់ដុល្លារទៅឱ្យម្តាយរបស់ខ្លួន ហើយពិធីភ្ជាប់ពាក្យគឺកើតក្រោយពេលដែលកើតហេតុកើតឡើង។ ជាងនេះទៅទៀតបើទោះបីជាគូដណ្តឹងនឹងគ្នាក៏ជនជាប់ចោទមិនអាចបង្ខំឱ្យជនរងគ្រោះរួមភេទជាមួយខ្លួនបានដែរ។

៨-ក្រុមប្រឹក្សាយល់ឃើញថា សាលក្រមព្រហ្មទណ្ឌលេខ ៤៥២ "វ" ក្រ៧ ចុះថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០១៦ របស់សាលាដំបូងរាជធានីភ្នំពេញ បានលើកយកសំអាងហេតុ និង សេចក្តីសម្រេចមកនេះមានលក្ខណៈត្រឹមត្រូវតាម



Scanned by CamScanner

ច្បាប់រួចហើយ គប្បីក្រុមប្រឹក្សាតម្កល់ទុកសេចក្ដីសម្រេចនេះជាបានការបានដដែល ។

## ហេតុដូច្នេះ

## វិនិច្ឆ័យសេចក្ដី

១-ទទួលបណ្ដឹងឧទ្ធរណ៍លេខ ៨២១ ចុះថ្ងៃទី ១១ ខែ វិច្ឆិកា ឆ្នាំ ២០១៦ របស់ជនជាប់ចោទឈ្មោះ [redacted] ឆាយលី ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយទាស់និងគតិច្បាប់ ។

២-តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ៤៥២ "វ" ក្រ៧ ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១៦ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការដដែល ។

៣-បន្តឃុំខ្លួនជនជាប់ចោទឈ្មោះ [redacted] ឆាយលី តាមនីតិវិធី។

៤-សាលដីកានេះជំនុំជម្រះជាអសាធារណៈនៅថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១៧ និងប្រកាសជាសាធារណៈ នៅថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១៧ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] ឆាយលី មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ និងដើមបណ្ដឹងរដ្ឋប្បវេណី ។

បើកប្ដឹងសាទុក្ខក្នុងកំណត់ច្បាប់ ។

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សា |
|---|---|---|
| ហត្ថលេខា [redacted] | ហត្ថលេខា [redacted] [redacted] | ហត្ថលេខា [redacted] |

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
រាជធានីភ្នំពេញ ថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៧
ក្រឡាបញ្ជី

បានឃើញ
ប្រធានក្រុមប្រឹក្សាជំនុំជម្រះ

[redacted]

[redacted]



Scanned by CamScanner